ភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

**សេចក្តីសំរេច លេខ ១០ សសរ**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

**********

- បានឃើញក្រឹត្យ ស្តីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្តោះអាសន្ន នៃកម្ពុជា របស់សម្តេចព្រះឧបយុវរាជនរោត្តម សីហនុ ប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងសេចក្តីសំរេចចិត្តរបស់សភាតំណាងរាស្ត្រទាំង ១២០ រូប ចុះថ្ងៃ ទី ០១ ខែ កក្កដា ឆ្នាំ១៩៩៣ ស្តីពីការតំកល់ទុកនូវច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជា ក្នុងនោះមានច្បាប់ ស្តីពីការវិនិយោគដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ៥៨ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ និងក្រឹត្យលេខ ៩២ ក្រ ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ១៩៩២

យោងសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត " គណៈកម្មាធិការជាតិវិនិយោគ "

**សំរេច**

ប្រការទោល ៖ សមាសភាពនៃគណៈកម្មាធិការជាតិវិនិយោគ ដែលមានចែងក្នុងប្រការ ១នៃសេចក្តីសំរេចលេខ ០៧ សសរ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ត្រូវបានបន្ថែមដូចតទៅ ៖

-ឯកឧត្តម អ៊ឹង ផន ឧបនាយករដ្ឋមន្ត្រី ជាសហប្រធាននៃគណៈកម្មាធិការជាតិវិនិយោគ ជាមួយ ឯកឧត្តម គាត ឈន់ ។

សហប្រធាន
រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា
ព្រះហស្តលេខា និង ហត្ថលេខា

ស្តេចក្រុមហ្លួង នរោត្តម រណឫទ្ធិ ហ៊ុន សែន